# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ ០០៤/២៣ ន.គ.ស គ.ក.គ.ក/ស.ម.៧.

ថ្ងៃព្រហស្បតិ៍ ១១រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៣

## សេចក្តីជូនដំណឹង

កម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ត្រូវបានដាក់ឱ្យអនុវត្តដោយប្រកាសលេខ៣១៨ សហវ.ប្រក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២០ ស្តីពីការដាក់ឱ្យអនុវត្តកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ កម្មវិធីសិក្សានេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា ហៅកាត់ថា **គ.ក.គ.ក.**។ អនុលោមតាមប្រការ៣ នៃសេចក្តីសម្រេចលេខ០០៣/២៣ ន.គ.ស.-គ.ក.គ.ក./ស.ស.រ. ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣ ស្តីពីការបង្កើតអនុគណៈកម្មាធិការអភិវឌ្ឍកម្មវិធីសិក្សា អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង អនុគណៈកម្មាធិការទទួលស្គាល់ការអប់រំនិងបណ្តុះបណ្តាល និងលេខាធិការដ្ឋាន នៃ **គ.ក.គ.ក.** បានចែងពីសមាសភាពរបស់អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង នៃ **គ.ក.គ.ក.** ដែលតម្រូវឱ្យមានបុគ្គលឯករាជ្យក្នុងវិស័យគណនេយ្យនិងសវនកម្ម ចំនួន០១ (មួយ)រូប ចូលជាសមាជិករបស់អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង ដើម្បីឱ្យការគ្រប់គ្រងការប្រឡងប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាព។ ដូចនេះ **គ.ក.គ.ក.** ត្រូវការជ្រើសរើសបុគ្គលឯករាជ្យដែលជាអ្នកជំនាញគណនេយ្យនិងសវនកម្ម ចូលរួមជាសមាជិកចំនួន០១ (មួយ)រូប ដើម្បីរួមចំណែកក្នុងការគ្រប់គ្រងនិងអភិវឌ្ឍកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា។ អាស្រ័យហេតុនេះ **គ.ក.គ.ក.** សូមជម្រាបជូនដល់សាធារណៈជនដែលមានជំនាញ ចំណេះដឹង និងបទពិសោធន៍ ក្នុងវិស័យគណនេយ្យនិងសវនកម្ម និងមានបំណងចូលរួមជាសមាជិក របស់អនុគណៈកម្មាធិការគ្រប់គ្រងការប្រឡង សូមអញ្ជើញដាក់ពាក្យស្នើសុំដោយបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

### ១. លក្ខខណ្ឌគុណវុឌ្ឍិសម្រាប់បេក្ខជន

- ត្រូវមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុឡើងទៅ ឬមានសញ្ញាបត្រវិជ្ជាជីវៈ (CPA, ACCA ឬCA)
- មានបទពិសោធន៍ខាងផ្នែកគណនេយ្យ ហិរញ្ញវត្ថុ សវនកម្ម ឬខាងអប់រំផ្នែកធុរកិច្ច យ៉ាងតិច ៧ ឆ្នាំ

### ២. សំណុំបែបបទដែលត្រូវបំពេញ និងឯកសារភ្ជាប់

- ពាក្យស្នើសុំ (Cover Letter)
- ប្រវត្តិរូបសង្ខេប (Curriculum Vitae)



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៥៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

- សញ្ញាបត្រថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

- លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ

- ឯកសារពាក់ព័ន្ធផ្សេងៗ (ករណីចាំបាច់)

### ៣. កាលបរិច្ឆេទ និងទីកន្លែងដាក់ពាក្យ

- កាលបរិច្ឆេទដាក់ពាក្យចាប់ពីថ្ងៃជូនដំណឹងនេះរហូតដល់ថ្ងៃទី២៦ខែ កក្កដា ឆ្នាំ២០២៣ វេលាម៉ោង៤:០០នាទីល្ងាច។

- ទីកន្លែងដាក់ពាក្យ និយ័តករគណនេយ្យនិងសវនកម្ម អគារ “ក” ជាន់ទី១ ក្នុងបរិវេណ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមទំនាក់ទំនង៖**

- ➢ លេខទូរស័ព្ទ និងតេឡេក្រាម៖ **០១៧ ៩៣៩ ៥៩២**
- ➢ សារអេឡិចត្រូនិច(Email) : **p.sokuntheary@acar.gov.kh**។

**គណៈកម្មាធិការគ្រប់គ្រងកម្មវិធីសិក្សាគណនេយ្យករជំនាញកម្ពុជា**